# ពួកសាក្សី

## សាក្សី #១

### ព្រះបន្ទូលរបស់ព្រះអម្ចាស់

យ៉ូសែប ស៊្មីធ បានទទួលបញ្ជាមិនឲ្យបង្ហាញផ្ទាំងមាសទៅកាន់ពិភពលោកឡើយ ( សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា ៥:៣ ) ។ សូមអាន គោលលទ្ធិ និងសេចក្តីសញ្ញា ៥:៦–១០ ដោយរកមើលអ្វីដែល យ៉ូសែប ទទួលបានការអនុញ្ញាតឲ្យចែកចាយ ។

អ្នកអាចនឹងចង់គូសចំណាំឃ្លាមួយដែលព្រះអម្ចាស់បានមានព្រះបន្ទូលឡើងវិញនៅក្នុង ខទី ៥, ៦ និង ៧ ។

- ហេតុអ្វីបានជាអ្នកគិតថា ព្រះអម្ចាស់មានការព្រួយបារម្ភអំពីយើងដែលកំពុងជឿលើ និងប្រុងស្តាប់ព្រះបន្ទូលរបស់ទ្រង់នៅក្នុងព្រះគម្ពីរមរមន ជាងទ្រង់ព្រួយបារម្ភអំពីយើងដែលដឹងថាផ្ទាំងមាសមានពិតប្រាកដមែនឬអត់នោះ ?

ដោយយោងទៅព្រះគម្ពីរមរមន ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–ឆ្នាំ ២០០៨ ) បានបង្រៀន ៖



ភស្តុតាងសម្រាប់សេចក្តីពិតរបស់ព្រះគម្ពីរនេះ សម្រាប់ភាពត្រឹមត្រូវរបស់ព្រះគម្ពីរនេះនៅក្នុងពិភពលោកដែលរហ័សនឹងទាមទាររកភស្តុតាង មិនមែននៅក្នុងបុរាណវត្ថុវិទ្យា ឬនរវិទ្យាទេ បើទោះបីជាទាំងនេះអាចនឹងមានប្រយោជន៍សម្រាប់មនុស្សមួយចំនួនក៏ដោយ ។ វាមិនស្ថិតនៅក្នុងការស្រាវជ្រាវពាក្យពេចន៍ ឬការវិភាគខាងប្រវត្តិសាស្ត្រនោះទេ បើទោះបីជាទាំងនេះអាចនឹងជាការបញ្ជាក់ក៏ដោយ ។. . . ការសាកល្បងនៃសេចក្តីពិតរបស់គម្ពីរនេះ គឺជាការអានវា ។ វាគឺជាព្រះគម្ពីររបស់ព្រះ ។ ( ហ្គរដុន ប៊ី ហ៊ិងគ្លី « Four Cornerstones of Faith » Ensign ខែវិច្ឆិកា ឆ្នាំ ២០០៤ ទំព័រ ៦ )

សូមចំណាយពេលពីរបីនាទីដើម្បីជញ្ជឹងគិតពីបទពិសោធន៍អ្នកក្នុងការសិក្សា និងទទួលបានការបង្រៀនពីព្រះគម្ពីរមរមន ។ សូមគិតអំពីរបៀបដែលការសិក្សារបស់អ្នក បានមានឥទ្ធិពលលើជីវិតរបស់អ្នក ។ អ្នកអាចចង់កត់ត្រាគំនិតមួយចំនួនរបស់អ្នកទៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។

## សាក្សី #២

### ទីបន្ទាល់នៃពួកអ្នកបម្រើបីនាក់

សូមអាន គោលលទ្ធិ និងសេចក្តីសញ្ញា ៥:១១–១៥ ដោយរកមើលថា តើនៅទីបំផុតព្រះអម្ចាស់នឹងអនុញ្ញាតឲ្យនរណាឃើញផ្ទាំងមាសនេះ ។

- តើអ្នកបានឃើញអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ ដែលអាចធ្វើឲ្យទីបន្ទាល់នៃពួកសាក្សីបីមានឥទ្ធិពល ?

ក្រោយមក ម៉ាទិន ហារិស , អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ បានឃើញផ្ទាំងមាស ហើយថ្លែងទីបន្ទាល់អំពីភាពពិតរបស់ផ្ទាំងមាស ។ អ្នកនឹងរៀនបន្ថែមទៀតអំពីព្រឹត្តិការណ៍នេះនៅពេលអ្នកសិក្សា គោលលទ្ធិ និងសេចក្តីសញ្ញា ១៧ ។

ដោយយោងទៅពួកសាក្សីបីនាក់ ប្រធាន ដាល្លិន អេក អូក ក្នុងគណៈប្រធានទីមួយបានបង្រៀន ៖



ទីបន្ទាល់របស់ពួកលោកមិនខុសគ្នាពីពួកសាក្សីផ្សេងទៀតឡើយ ។ មនុស្សម្នាក់អាចបដិសេធបាន ប៉ុន្តែតើមនុស្សម្នាក់ពន្យល់មនុស្សបីនាក់ដែលមានបុគ្គលិកលក្ខណៈល្អត្រឹមត្រូវ ដែលរួបរួម និងខិតខំនៅក្នុងការបោះពុម្ពទីបន្ទាល់នេះរហូតដល់ចុងបញ្ចប់នៃជីវិតរបស់ពួកលោក ដែលប្រឈមនឹងការចំអកឡកឡើយដ៏ខ្លាំងក្លា និងទំនាស់ផ្ទាល់ខ្លួនផ្សេងទៀតដោយរបៀបណាទៅ ? ដូចគ្នានឹងព្រះគម្ពីរមរមនដែរ គ្មានការពន្យល់ណាដែលប្រសើរជាងការផ្តល់ឲ្យដែលមាននៅក្នុងទីបន្ទាល់នោះតែម្តង ដែលជាសេចក្តីថ្លែងការណ៍ដ៏ឧឡារិកនៃបុរសដ៏ល្អ និងស្មោះត្រង់ ដែលបានប្រាប់ពីអ្វីដែលពួកលោកបានឃើញ ។ ( ដាល្លិន អេក អូក « The Witness: Martin Harris » Liahona ខែ ឧសភា ឆ្នាំ ១៩៩៩ ទំព័រ ៣៦ )

សូមពិចារណាអាន « ទីបន្ទាល់នៃពួកសាក្សីបីនាក់ » នៅដើមព្រះគម្ពីរមរមន ឬធ្វើបញ្ជីឈ្មោះនៃបុគ្គលដែលបានថ្លែងទីបន្ទាល់ដល់អ្នកថា ព្រះគម្ពីរមរមនគឺពិត ។ សូមគិតអំពីរបៀបដែលទីបន្ទាល់ពួកគាត់បានពង្រឹងដល់ទីបន្ទាល់របស់អ្នក ។

## សាក្សី #៣

### ព្រះវិញ្ញាណបរិសុទ្ធ

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៥:១៦ និង ម៉ូរ៉ូណៃ ១០:៤–៥ ។ សូមស្វែងរកពីរបៀបដែលព្រះបើកបង្ហាញពីសេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរមរមនដល់បុត្រាបុត្រីរបស់ទ្រង់ ។

- តើមានរបៀបណាខ្លះដែលព្រះវិញ្ញាណអាចនឹងថ្លែងទីបន្ទាល់ចំពោះនរណាម្នាក់អំពីសេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរមរមន ?

ហ្គ្លេន អិល ផេស ដែលបានបម្រើជាប៊ីស្សពជាអធិបតីបានមានប្រសាសន៍ ៖



> គ្មានរបៀបផ្សេងណាដើម្បីទទួលបានទីបន្ទាល់ ក្រៅពីតាមរយៈសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធឡើយ ។ អ្នកមិនអាចពឹងផ្អែកលើអ្វីផ្សេងទៀតបានទេ ។ . . . យើងមានឧទាហរណ៍ជាច្រើនមកពីព្រះគម្ពីរ អំពីភាពឥតន័យដែលការបើកសម្ដែងផ្ទាល់ភ្នែកអាចមាន បើគ្មានការទទួលសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធមកជាមួយទេនោះ ។ ការប្រែចិត្តជឿមិនកើតឡើងតែតាមរយៈការបើកសម្ដែងផ្ទាល់ភ្នែកពីស្ថានសួគ៌នោះទេ ។ ( ហ្គ្លេន អិល ផេស « The Elusive Balance » New Era ខែ មីនា ឆ្នាំ ១៩៨៩ ទំព័រ ៤៩ )

សូមធ្វើបញ្ជីនៃហេតុផលដែលអ្នកគិតថា សាក្សីពីព្រះវិញ្ញាណបរិសុទ្ធដែលជាសមាជិកនៃក្រុមព្រះសំខាន់ជាងភស្តុតាងជាក់ស្ដែងដែលថាអ្វីមួយពិត ។ សូមពិចារណាបញ្ចូលសាក្សីណាមួយដែលអ្នកមានអារម្មណ៍ថា អ្នកបានទទួលតាមរយៈព្រះវិញ្ញាណបរិសុទ្ធថា ព្រះគម្ពីរមរមនគឺជាការពិត ។


© 2024 by Intellectual Reserve, Inc. All rights reserved.
PD80007812_258_053-1